# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៧ សសរ

## សេចក្តីសំរេច
## ស្តីពី
## ការប្រគល់សិទ្ធិ

៳៣*៳៳

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១.-** ត្រូវបានប្រគល់សិទ្ធិ ជូនឯកឧត្តម **ឡោក់ សុខុន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល និង ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ជាអ្នកសំរបសំរួលគំរោងសិក្សា ស្តីពីការពង្រឹងមុខងារសាធារណៈតាមរយៈការកែលំអការចំណាយសំរាប់គ្រប់គ្រងធនធានមនុស្ស ជំនួសឯកឧត្តម **ស៊ុំ ម៉ាន់ត** ដែលត្រូវ ទៅព្យាបាលសុខភាពរយៈពេលវែង នៅប្រទេសបារាំង ។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានក្រុមប្រឹក្សា អាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញៈថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួលៈ*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ "២"*
- *កាលប្បវត្តិ-ឯកសារ*